ហាន់ដាជាមនុស្សឆ្លាត នាងដឹងគេនេះកំពុងស្លុបមុខក្នុងកាមតណ្ហាទៅហើយ សម្ដីគេមិនបាច់យកមកគិតក៏បាន តែចរិតមានះរបស់គេអាចនឹងពិបាកទប់ទល់ ប្រសិននាងបន្តវ៉ានិយាយត្រូវខុស។

តែរកនឹកដោះស្រាយមិនទាន់បានស្រួលផង បុរសលោបបបូរមាត់មកទៅហើយ ។ នាងរុញគេចេញតែមិនបានការទេចំណែកការបិទបបូរមាត់រារាំងគេក៏មិនដឹងជាបានយូរប៉ុណ្ណាដែរ។

នៅចំកណ្ដាលនៃភាពគួរឱ្យអស់សំណើចនេះ បុរសមានវិធីដែលគេដឹងថានឹងយកឈ្នះចិត្តដ៏រឹងរបស់នាង តែនាងវិញចាប់អារម្មណ៍ថាខ្លួនឯងម្ដងៗសឹងតែតបតនឹងសេចក្ដីស្នេហានេះ ទោះបីខួរក្បាលប្រាប់ថា កុំ! គេនេះមិនមែនជាមនុស្សល្អ! មនុស្សមិនធ្វើអ៊ីចឹងទេ! ឯងនឹងរងគ្រោះគេមកជាអ្នកណាជាមនុស្សខាងជំទាវនារីភាក៏មិនដឹង? រូបឯងអាចនឹងត្រូវគេផ្សាយចេញថា មកលបលួចថើបជាមួយប្រុសផ្សេងក្រោយប្ដីស្លាប់មិនដល់២ខែ! អ៊ូព្រះ!

«ខ្ញុំរៀបការរួចហើយគីម៉ាល់ ខ្ញុំមានប្ដីហើយ!»

ទ្រូងគេលោតភឹបនឹកដល់ប្អូនកម្សត់។ ពីចំហៀងខាងស្ដាំ ស្រមោលមនុស្សបង្ហាញខ្លួន ពីក្រៅកញ្ចក់។ ស្នូរជាន់ទូកគ្រឹបៗ ដូចការគ្រោងទុក......

គីម៉ាល់ជ្រួញចិញ្ចើមគិត គេដឹងថាត្រូវធ្វើអ្វីនៅពេលនេះ។

ម្រាមដៃបុរសរាវក្នុងចង្កេះនាងរកស្រទាប់អាវ ហើយទាញភ្លោចមកលើបម្រុងដោះវាចេញ តែត្រូវនាងប្រកែកប្រណាំងប្រតោងប្រទាម។

គេដឹងថាមនុស្សទាំងអស់នឹងមកដល់ទីនេះ ចំណែកខាងស្រីមិនបានដឹងអ្វីក្រៅពីការចាញ់ប្រៀបដែលមិនយូរប៉ុន្មាន នាងនឹងមានបញ្ហាធំ ។

ក្នុងនាមជាចំណាប់ខ្មាំង នៃឆាកស្នេហ៍ទាំងមិនដឹងរឿងនិងមិនសុខចិត្ត នាងក្ដិចខ្វាំនាយលើកជើងមកបុកទម្លាយរបាំងស្នេហ៍ក្រាសឃ្មឹករបស់នាយតបតយ៉ាងណាកំផែងនោះនៅតែរឹងមាំជាប់ប៊ឹងហាក់មិនចេះឈឺ មិនចេះរង្គើ មិនចេះរលាយ។

«ខ្ញុំគ្មានថ្ងៃស្រឡាញ់ខ្លួនឯងទេ ឮនៅមនុស្សអត្មានិយម មនុស្សមិនចេះគិតអ្នកដទៃ!»

នាងខាំមាត់ថាស្ដីឱ្យបុរសនេះតែមិនដឹងគេឮច្បាស់ឬអត់ទេព្រោះនាងកំពុងនិយាយទាំងគេចប្រផុតប្រផើយពីបបូរមាត់នាយ។

មនុស្សមកកាន់តែកៀក ខាងស្រីហាក់មិនងាយសម្រួប គេមានតែច្បាមរាងកាយនាងជាប់ជាងមុនតឹងជាងមុនហើយខ្សឹបសម្លុតៈ

«ឈប់រើ ឈប់ស្រែក ពួកនារីភាទ្បើងមកហើយ!»

ឮឈ្មោះម្ដាយក្មេករបស់ខ្លួន នាងឈប់ភ័យតក្កមា បែរជាភាំងចលនា។ ស្រីតូចរបូតដៃខ្លាកពីការប្រជែងច្រានរាងកាយនាយ ។ ជាមួយកែវភ្នែកមូលក្លំសម្លឹងគីម៉ាល់ នាងកំពុងភាន់ភាំងចំពោះសំនួរថាហេតុអ្វីម្នាក់ចំពោះមុខខ្លួននេះស្គាល់ឈ្មោះម្ដាយពិសិដ្ឋហើយហៅស្និទ្ធស្នាលកម្រិតនេះ?

គេជាមនុស្សដែលក្រុមនោះបានចាត់មក ហើយឈុតឆាកទាំងអស់មិនមែនកើតឡើងព្រោះស្នេហាចៃដន់ទេ?

ស្នូររុញទ្វារក្ដាំង តែមិនកម្រើកចូលមកក្នុងបានដោយសារគេជ្រែងជើងរាំង។ កណ្ដាលភាពភាន់ភាំងមិននិយាយស្ដីរបស់ខាងស្រី ដៃខាងប្រុសដោះអាវខ្លួនគេខ្លួនឯងចេញនទោលគោក ហើយលូកខ្វាកទៅទាញរហែកវាំងននស្រាលស្ទើកលើបង្អួចកញ្ចក់។ បានរបស់ដល់ដៃ គេពន្លែងជើងបណ្ដោយឱ្យទ្វារបុកចូលមកក្នុងបានតាមសន្ទុះចិត្តភ្ញៀវ ស្របពេលរាងកាយប្រុសស្រីទាំងទ្វេ រុំត្រសុសចូលគ្នាក្រោមផ្ទៃសំពត់វាំងននវែងអន្លាយ។

មនុស្សមានប្រុសមានស្រីបានបង្ហាញវត្តមានច្រើនគ្នានៅមាត់ទ្វារបន្ទប់ ។ ពួកគេសម្លឹងអ្នកទាំងពីរនៅក្នុងសំណុំវាំងននតែមួយ ដែលអ្នកណាៗក៏ មើលទៅដូចជាខ្លួនប្រាណពួកគេកំពុងអាក្រាតជាមួយគ្នាដូច្នោះដែរដែរ។

ជាមួយកែវភ្នែកដែលបង្ហាញអារម្មណ៍មិនស្រួល ស្ត្រីវ័យក្មេងក្នុងទម្រង់សក់ទាន់សម័យខ្លីលើកញ្ចឹងកបើកភ្នែកធំៗដោយភាពភ្ញាក់ផ្អើលសម្លឹងមកគីម៉ាល់។ នាងលាន់មាត់ហៅគេតិចៗៈ

«ពិស័ក!»

តាមថាហាន់ដាហៀបនឹងហៅរកស្ត្រីនោះឱ្យជួយរំដោះខ្លួនទៅហើយ ស្រាប់តែមកឮឈ្មោះមួយនេះ នាងក៏បង្វែរទិសដៅ ងើបមុខយឺតៗមកសម្លឹងបុរសម្ចាស់បន្ទប់វិញ។

ជាមួយកែវភ្នែកខ៉ឺដង រេមើលនាងដូចគូស្នេហ៍ពិតៗ គីម៉ាល់មិនបានធ្វើរវល់ជាមួយការភ្ញាក់ផ្អើលរបស់នារីសក់ខ្លីទេ ។ ក្រៅពីជះពន្លឺភ្នែកពេញដោយសេចក្ដីស្រឡាញ់មកកាន់ម្ចាស់រាងកាយ ដែលខ្លួនទើបបានគ្រប់គ្រងអម្បាញ់មិញនេះ ដៃទាំងទ្វេគេថែមទាំងលូកក្រសោបចង្កេះនិងត្រគាកនាងទៀត។

នារីសក់ខ្លីនិងបក្សពួកហាក់កើតទោសៈ តែក៏កំពុងភ្ញាក់ផ្អើលខ្លាំងមួយជាន់ទៀតដែរ។ ពេលហាន់ដាខំកម្រើករើពីរង្វង់ដៃគីម៉ាល់ ប្រុសស្អាតកាន់តែមានៈ លោច្រមុះមកថើបសក់នាងដោយផ្ចេចភ្នែកទាំងសងសំធំស្រង់ក្លិនកេសាស្រី ហាក់មិនរវល់នឹងភ្នែកមនុស្សម្នា ធ្វើដូចជាទីកន្លែងនេះមានតែទេសភាពទន្លេមេគង្គនិងរាងកាយស្អិតរមួតទាំងទ្វេអង្គប៉ុណ្ណោះ។

«ស្រីថោកទាប! ប្ដីស្លាប់មិនទាន់ធ្វើបុណ្យគ្រប់ផង មកសំងំឱបប្រុសសា.....»

ទំនងនារីនេះចង់បន្ថែមពាក្យសាហាយឱ្យចប់ដែរប៉ុន្តែការបើកភ្នែកមកវិញរបស់គីម៉ាល់ធ្វើឱ្យមាត់នាងអាក់។

នាងហាក់មានឫកពាទោរទន់ជាមួយបុរសនេះ។ ឯហាន់ដាវិញកាន់តែទទួលអារម្មណ៍ដូចកំពុងធ្លាក់នរកជ្រៅ។

«ម៉ាក់ក្មេក! មិនមែនដូចម៉ាក់ឃើញទេ!»

នាងខំនិយាយ ខណៈខាងប្រុសញញឹម និងមិនដកច្រមុះចេញពីសរសៃសក់ទន់ស្មើសូត្ររបស់គូស្នេហ៍ក្នុងដៃ។

«គឺវាលើសពីអ្វីដែលលោកជំទាវកំពុងឃើញផង លោកជំទាវ»

គីម៉ាល់និយាយបន្ថែមបន្តពីហាន់ដា ក្រោមកែវភ្នែកកំហឹងក្ដៅគគុកនៃនារីសក់ខ្លី។ ខណៈហាន់ដាខំរើ គីម៉ាល់កាន់តែលូកដៃជ្រៅទៅរកចំណុចខ្សោយរបស់នាង ធ្វើឱ្យស្រីស្អាតស្រឡាំងកាំងនឹងភាពអនាចារនៃបុរសនេះ។ ត្បិតតែគ្រប់យ៉ាងព័ទ្ធដោយស្បៃវាំងនន តែភាពមានៈរបស់គេកំពុងធ្វើឱ្យនាងគាំងចង្វាក់ដង្ហើមម្ដងៗ។

«គីម៉ាល់ ឆាប់លែងដៃ!»

នាងបញ្ជាដោយខាំមាត់។ ទឹកមុខងើលឌីរបស់ខាងប្រុសរឹតតែធ្វើឱ្យជំទាវសក់ខ្លីផ្ទុះទោសៈ១០០អង្សា។

«គ្រួសារយើងនឹងប្ដឹងនាងរឿងអនាចារនេះ ហើយដកហូតសិទ្ធិមរតកទាំងអស់ពីនាងមកវិញ! មួយសេនក៏គ្មានសម្រាប់ស្រីមុខក្រាស់ឯងដែរ!»

នាងស្រឡាំងកាំងលែងរើលែងបម្រះអ្វី។

គេនេះនឹងមនុស្សគ្រួសារប្ដីនាងបានរៀបអន្ទាក់នេះឡើងដើម្បីសម្លាប់នាងឱ្យរើខ្លួនលែងរួចពិតមែនដែរទេ?

ចុងក្រោយបង្អស់នាងត្រូវមកចាញ់បោកពួកគេកណ្ដាលទន្លេមេគង្គតែម្នាក់ឯងកណ្ដាលហ្វូងចចកពិត គឺចាញ់ទាំងអយុត្តិធម៌ទាំងអាម៉ាស់បែបនេះមែនដែរទេ។

ដោយលែងឮសំឡេងកូនប្រសារ ជំទាវក្មេងស្រស់ស្អាតដែលមិនដកភ្នែកពីទឹកមុខសង្ហាឥតខ្ចោះនៃបុរសម្ចាស់ទូក ខាំមាត់និយាយបន្តទាំងកំហឹង៖

«បើឯងមិនចង់ឱ្យគ្រប់គ្នាឃើញរូបភាពប្រុសស្រីក្នុងវាំងននតែមួយលើទំព័រមុខកាសែតនៅថ្ងៃស្អែកនេះទេ ឈប់ជាន់ភ្នំពេញ ហើយលាចាកពីកម្មសិទ្ធិផងទាំងឡាយដែលមេធាវីទើបនឹងបើកលិខិតបណ្ដាំកាលពីម្សិលមិញ!»

ខ្លួននាងត្រជាក់ដូចទឹកទន្លេក្នុងរង្វង់ដៃនាយ។ គ្រប់យ៉ាងដូចការគិតទុក នាងមិនទាន់ទៅដល់សុងសក្ដិផង ហេតុកាណ៍បានកើតឡើងហួសទៅហើយ។ គ្រប់យ៉ាងរលាយហើយ។

«ប្រើល្បិចអស្ចារ្យណាស់! ចង់បានមរតកតើហ្អី ម៉េចចាំលេងល្បិចថោកទាបម្ល៉េះ?»

នាងនិយាយទាំងស្រក់ទឹកភ្នែកម៉ាត់ៗកំដរប្រអប់ដៃនាយ ធ្វើឱ្យបេះដូងខាងប្រុសអាណោចអាណិត។ គេឱនខ្សឹបខ្សៀវក្បែរត្រចៀកស្រីលាយឡំជាមួយស្នាមថើបដោយក្ដីស្រឡាញ់អាណិត៖

«កុំយំមើល៍! គេសម្លុតប៉ុណ្ណឹងយំបាត់ហើយ អ្នកស្នងមរតកម្នាក់នេះ!»

នាងយំកាន់តែខ្លាំងព្រោះទប់ចិត្តអាណិតខ្លួនឯងមិនជាប់។

ហាន់ដាអើយហាន់ដា! ឆ្លាតណាស់ដែរ តែទេសកាលអីត្រូវមកចាញ់កលគេជាមួយសន្ធូចប្រុសស្អាតទីបំផុតទៅឯងលែងជាន់ភ្នំពេញបានពិតមែន ថែមទាំងមកត្រូវគេរឹបអូសផលបុណ្យទាំងពួងជាមរតកចុងក្រោយរបស់ស្វាមីកម្សត់ផង។

នាងគិតហើយខ្សឹកខ្សួលកាន់តែខ្លាំងឡើងក្រោមភាពបានចិត្តនៃពួកមនុស្សលោភ។ ជំទាវបែរខ្នងចាកចេញទៅក្រោយពីបានសម្លឹងប្រុសស្អាតមួយឆ្វាច់ចុងក្រោយដោយកំហឹង ។

មនុស្សទាំងអស់ចេញតាមនាងដែរ។ ហាន់ដាយល់ថា គ្រប់យ៉ាងម្ដាយក្មេកវ័យក្មេងម្នាក់នេះបានរៀបចំច្បាស់លាស់ណាស់ហើយ ។

ពេលនេះអ្វីៗបានដូចបំណងគេហើយ។

ប្រុសសង្ហាលែងហត្ថទាំងទ្វេពីកាយស្រី ទុកឱ្យនាងនៅទន់ជើងអង្គុយប៉ុកលើគ្រែតែម្នាក់ឯង។ គេពាក់អាវបណ្ដើរចាកចេញក្នុងដំណើរមួយៗទៅតាមពីក្រោយក្រុមមនុស្សអភិជនបណ្ដើរ។

សំឡេងគីម៉ាល់លាន់មកពីក្រៅបន្ទប់៖

«អ្នកណាបញ្ជោញរូបទៅឱ្យកាសែត អ្នកណាចង់បានមរតករបស់ហាន់ដា អ្នកហ្នឹងមានរឿងជាមួយខ្ញុំ!»

ពួកមនុស្សនៅខាងក្រៅទំនងជាបង្អង់ឈប់បន្តដំណើរ។

សំឡេងម្ដាយក្មេករ័យក្មេងដែលហាន់ដានៅចំណាំច្បាស់ លាន់មកផ្ទាន់សួរគីម៉ាល់៖

«ប្រុសធំចង់ថាអ្នកណាហាន់ដា?!»

«ប្រុសធំ?» នាងគិតភ្លែតក្នុងបេះដូងដែលកំពុងក្រៀមស្រពោន។

មែនហើយ! មុននេះជំទាវបានភ្លាត់មាត់ហៅឈ្មោះគេថា ពិស័ក ម្ដងហើយ ពេលនេះពាក្យប្រុសធំ គឺកាន់តែច្បាស់ឡើង។ គេជាបងប្រុសបាត់ខ្លួនរបស់ពិសិដ្ឋ?

គេនេះហ្អី? ជាបងថ្លៃដែលល្បីថាកំណាច មួយឆ្នាំមិនទាន់និយាយរកអ្នកណាមួយម៉ាត់នោះ។

ហាន់ដាក្ដាប់ដៃទាំងសងតតាំងនឹងអារម្មណ៍រំជួល។

«នីដាក៏ដោយហាន់ដាក៏ដោយ! គេជាប្រពន្ធខ្ញុំ ជាមនុស្សខ្ញុំឱបជាប់ទ្រូង! មរតកគេ កិត្តិយសគេ ជាមរតកខ្ញុំនិងកិត្តិយសខ្ញុំ អ្នកណាមិនសុខចិត្តចង់តតាំងជាមួយគេ ត្រូវតតាំងជាមួយខ្ញុំ!»

ស្រីស្អាតអង្គុយធ្មឹងដោយអស់សង្ឃឹម។

ឯងចប់ហើយហាន់ដា! បងថ្លៃឯងក៏ឯងលេងល្បែងស្នេហ៍ជាមួយដែរ។ គេមើលមកឯងក្នុងសភាពជាស្រីអន់ៗកម្រិតណាទៅ? ហើយពេលនេះ ចំនួនអ្នកចង់បានមរតកក៏ចេញមុខមកច្រើនឡើងៗ ឯងរស់ដល់ស្អែកដែរអត់ទេ?

ជាមួយសភាពរាងកាយខ្សោះខ្សោយទន់ជ្រាយលាយក្ដីអាម៉ាស់ងងឹតមុខ នាងលែងដឹងថាត្រូវនិយាយអ្វីនិងតតាំងជាមួយពួកគេរបៀបណាហើយ។

សំឡេងជំទាវបន្លឺតបជាមួយគីម៉ាល់ទៀត តែម្ដងនេះរញ៉ីរញ៉ៃខ្លាំងហាក់បីដូចជាម្ចាស់សំឡេងពុះពោរទៅដោយកំហឹង៖

«អ្ហ៎ សម័យកាលនេះទំនើបរកតាមមិនទាន់មែន! ប្អូនស្លាប់មិនទាន់បាត់ផ្សែងធូប ផ្ទេរប្រពន្ធឱ្យបងប្រុសរួចរាល់ទៅហើយហ្ន៎!»

«ឬមួយលោកជំទាវមិនសុខចិត្ត ដែលគ្មានអ្នកណាព្រមផ្ទេររបស់ទាំងអស់នេះជូនលោកជំទាវ?»

«ប្រុសធំ!»

ស្ត្រីអភិជនគំហកតែត្រូវបាត់មាត់វិញធ្វើឱ្យទឹកភ្នែកហាន់ដូរហូរធ្លាក់ចុះច្រោកៗ កណ្ដាលជម្លោះនៃពួកអ្នកមានចិត្តជាលុយ។

នាងនឹកដល់ពិសិដ្ឋមនុស្សល្អបំផុតម្នាក់ក្នុងជីវិតនេះ ដែលនាងមិនដែលបានតបស្នងការស្រឡាញ់សម្រាប់គេ ហើយបានប្រគល់គ្រប់យ៉ាងមកឱ្យនាង តែនាងមិនចេះថែរក្សា។

«ត្រូវចាំថា លោកចេញចោលផ្ទះយូរហើយពិស័ក លោកគ្មានសិទ្ធិ គ្មានសំឡេង និងគ្មានអ្វីត្រូវនិយាយគ្នាទេ!»

«ប្រាកដអត់លោកជំទាវម្ដាយចុង?!»

សំឡេងគេសួរផ្ទាន់វិញធ្វើឱ្យហាន់ដានឹកឃើញ។

ត្រូវហើយ! ធ្លាប់មានម្ដងនាងឮពិសិដ្ឋនិយាយប្រាប់។ ព្រោះតែមិនពេញចិត្តនឹងអាពាហ៍ពិពាហ៍លោកឪពុកដ៏ចំណាស់ជាមួយប្រពន្ធដ៏ក្មេងខ្ចីម្នាក់នេះ ពិស័ក បានចាកចេញមិនដែលវិលមកផ្ទះវិញទេ។ សូម្បីថ្ងៃដែលពុកគេឈឺធ្ងន់ជិតស្លាប់ ប្អូនគេបានតាមរកច្រើនដង គេនៅតែមិនបង្ហាញខ្លួន។

ចុះហេតុអីពេលនេះម៉ោងនេះ គេមកនៅស្រុកខ្មែរហើយមានរឿងជាមួយនាង ហូរហែវែងដល់ម្លឹង? ជំទាវនៅខាងក្រៅស្រាប់តែលែងនិយាយស្ដី។

ទំនងជាគិតៗទៅ គឺម៉ាល់ម្នាក់នេះជាសាច់ឈាមសេសសល់តែមួយគត់របស់គ្រួសារប្ដីខ្លួន។ ឥឡូវនេះទៀតសោត បើគេវិលមកវិញជ្រោមជ្រែងភរិយារបស់ប្អូនប្រុសក្នុងការទទួលបានសម្បត្តិមហាសាលក៏ជាឧបសគ្គមួយធំទៅហើយ ចុះទម្រាំបើទាំងពីរនាក់មានសម្ព័ន្ធភាពស្នេហាទៀតរឿងអីថាងាយផ្ដួលនោះ?

មិនដឹងគិតដល់ល្បិចអ្វីថ្មី លោកជំទាវបែរជាទម្លាក់សំឡេងហើយនិយាយមួយៗវិញ៖

«ប្រុសធំពិចារណាផង មុនយកខ្លួនទៅបៀតមនុស្សស្រីប្រភេទនេះ ! មើលចុះតើពិសិដ្ឋអពមង្គលកម្រិតណាដែលមានៈរៀបការនាំនាងចូលមក រហូតស្លាប់ទាំងខ្លួនឯងសូន្យ?!»

អ្នកដែលត្រូវទ្រាំអង្គុយស្ដាប់គេជៀល គ្មានអ្វីក្រៅតែពីទោមនស្សយំរហាម លែងខ្វល់ថានេះជាគ្រែអ្នកណា បន្ទប់អ្នកណា។ ហាន់ដាប្រះដេកចុះទាំងទន់អស់ដៃជើងខ្លួនប្រាណ។

ទុក្ខព្រួយនិងភាពវាយប្រហារផ្លូវចិត្តធ្ងន់ៗបណ្ដាលឱ្យនាងលង់លក់មួយភាំងទៅក្រោមអំណាចនៃខ្យល់ទន្លេទុកឱ្យពួកមនុស្សចិត្តខ្លាំងគេតតាំងគ្នារហែកមេឃទៅចុះ។

**បេះដូងប្រុសម្នាក់នេះ**

សូរសំលេងបក្សាទ្រហឹងរំលសន្និយា បានដាស់នាងក្រោកឡើងសន្សឹមៗពីការលង់លក់។

នារីបើកភ្នែកព្រឹមៗ រេសម្លឹងរកនឹកមើលថានាងនៅឯណា កន្លែងណា?

សភាពទុក្ខព្រួយ ឈឺចាប់ផងទាំងឡាយបន់ឱ្យក្លាយជាការយល់សប្ដអាក្រក់ទៅចុះ ប៉ុន្តែមិនមែនទេ ត្រឹមតែមួយដង្ហើមពីរ នាងស្គាល់ទីនេះបន្ទប់នេះ ទីកន្លែងដែលស្នាមថើបដំបូងរបស់នាងបានរក្សាទុកនៅ ក៏ជាការប៉ះពាល់ជ្រៅបំផុតមួយរវាងនាងនិងមនុស្សប្រុសក្នុងជីវិតនេះ។

ស្រីស្អាតស្ទុះក្រោក តែក្បាលដែលធ្ងន់ដូចបានទូលអង្ករមួយល្អី បង្ខំនារីឱ្យអង្គុយជ្រួញថ្ងាស ច្របាច់ឈ្លី ព្រោះគ្រប់យ៉ាងឃ្លេងឃ្លោងខ្លាំង។

ទូកមិនបានឈប់នៅកំពង់ដក្រចេះទេ នាងដឹង។

សន្ទឹកម៉ាស៊ីនបានបង្ហាញថា ទូកមិនបានឈប់នៅឡើយ។

យើងទៅណា? គេយកយើងទៅកន្លែងណ៎ា ព្រះ?

រៀបរយសម្លៀកបំពាក់ ដោយភាពតក់ស្លុត ស្រីល្អស្រវាស្រទេញចាប់យកកាបូបដៃ និងទូរសព្ទដែលដេកស្ងៀមលើកម្រាល។

សុងសក្តិ Miscalled ២៨ដង?

គេមានៈដែលមិនឃើញនាងតប តែគេទំនងជាមានៈមិនដល់ម្នាក់ដែលនៅខាងក្រៅទេ!

នាងដើរចេញមកមួយៗ។

មិនដឹងថាត្រូវប្រឈមជាមួយបងថ្លៃព្រានដៃឆើតនោះរបៀបណា តែទោះរបៀបណាក៏ត្រូវតែប្រឈម ។

បុរសសង្ហានៅក្បាលទូក និយាយជាមួយមនុស្សរបស់គេ។ ពេលក្រឡេកឃើញនាង គេដើរត្រឡប់មកវិញភ្លាម។

នាងនៅជំអក់លែងបោះជំហានហើយឱនសម្លឹងដៃខ្លួនឯងជាជាងមើលមុខមនុស្សបំពានស្រីដូចគេ។ គេមកដល់កាន់តែកៀក បេះដូងស្រីកាន់តែលោតពិបាកគ្រប់គ្រង។

ឯងភ័យធ្វើអីនីដា? គេជាមនុស្សចង្រៃម្នាក់ ហេតុអីឯងត្រូវមានសម្ពាធហេតុអីត្រូវចាញ់បោកគេ។

«ជុំកទ័រគេងលក់ស្រួលអត់?!»

ទីបំផុត គេដឹងប្រវត្តិនាងហើយ។ គេឌឺដងលែងជាសុភាពបុរសដូចកាលពីជួបព្រឹកមិញទៀតហើយ។ ទោះនាងមិនទាន់រៀនពេទ្យចប់តែការងារនាង ផ្អែកលើវិស័យនេះ ការហៅរបស់គេ គឺឌឺដងបង្ករឿងពិតណាស់។

នាងនៅស្ងៀមបន្តិច ខាងគេក៏នៅស្ងៀម។

នាងខំប្រមូលភាពក្លាហានងើបមុខសម្លឹងតទល់។ បបូរមាត់រលោមរបស់គេដែលមុននេះងើលបង្កសង្គ្រាមដល់ថ្នាក់នាងត្រូវចុះចាញ់ លើកដៃសំពះ ពេលនេះក៏នៅជិតគ្នាបង្អើយ ហើយផ្តល់មកឱ្យនាងនូវស្នាមញញឹមតិចៗ ហាក់បង្កប់អត្ថន័យល្មមឱ្យស្រីមិនចង់ឃើញមុខគេ។

នាងខំណាស់ គឺខំធ្វើដូចក្លាហាន សម្លឹងគេមិនដកភ្នែកជាមួយសម្តីសង្កត់ពាក្យ៖

«គិតនាំខ្ញុំទៅណា? មិនឮខ្ញុំថា ចង់ចុះនៅក្រចេះទេ?!»

សំឡេងនាងនៅតែពីរោះទោះបីមានរឿងធំប៉ុនណា។ នារីនេះមានឫកពាសុភាពថ្លៃថ្នូរជានិច្ចក្នុងភ្នែកនាយ ទោះបីនាងរាងសិចស៊ីនិងរោលរាលបន្តិចពេលដែលសើចកក្អឹកដាក់ប្រុសមិនស្គាល់គ្នាកាលពីព្រឹក តែអំណោយទាននាង មានច្រើនជាងចំណុចខ្វះ។ ទោះយ៉ាងណាចិត្តស្នេហាបណ្តាលឱ្យគេចង់តែលេងជាមួយនាង៖

«នេះទូករបស់ខ្ញុំដុកទ័រ! ខ្ញុំចង់ជិះមួយខែពីរខែអត់ឡើងគោកវាស្រេចតែខ្ញុំ! មិនចាំបាច់សុំអ្នកណាអនុញ្ញាត មិនបាច់សួរថា អ្នកណាចង់ចុះនៅឯណាទាំងអស់!»

នាងខឹងដល់ថ្នាក់ទ្រូងពើងទាំងសងពើតដង្ហក់។ បុរសនេះ ជាមនុស្សសរសៃប្រសាទហើយមានមានតែមនុស្សសំណាងត្រឹមសូន្យប៉ុណ្ណោះដែលនៅមិននៅឡើងមកជិះទូករបស់គេ ឱ្យគេធ្វើទុក្ខបុកម្នេញ។

នាងទោមនស្សពេក ភ្នែកទាំងសងដែលសម្លក់គេត្រូវរលើបរលោង សឹងមើលមុខឌឺរបស់គេលែងឃើញ សំឡេងក៏ទើរត្រឹមបំពង់ក ដោយមិនអាចនិយាយស្តីតទល់អ្វីចេញ។

«អ៊ីចឹងសោះយំដែរ?»

បុរសពោលខ្សឹបៗដាក់កែវភ្នែកនាង ធ្វើឱ្យស្រីស្អាតលើកដៃជូតរ៉ាវជាសញ្ញាបដិសេធ។ ហាន់ដាមិនឆ្លើយអ្វីបន្ត ព្រោះតែកំពុងតឹងទ្រូងតូចចិត្ត។ ដោយនឹកឃើញដល់សម្ដីគេកាលពីព្រឹក «កុំភ័យ! ខ្ញុំជូនដាដល់ផ្ទះ!» នាងរឹតតែនិយាយលែងចេញ។

«លោកជាមនុស្សប្រុសធ្វើអីគិតគេជាស្រីផងគីម៉ាល់!»

ទីបំផុតនាងនិយាយពាក្យក្នុងចិត្តចេញមកបានទាំងអួលណែន។ នាងហៅឈ្មោះគេម្ដងជាពីរដង ទាំងដឹងថា គេមិនមែនគីម៉ាល់ទេ ជាពិស័ក បងថ្លៃដែលនាងកំពុងភ័យខ្លាច។ ទោះយ៉ាងណាខាងប្រុសដឹងថា នាងចូលចិត្តឈ្មោះនេះ។

គេដៀងភ្នែកសម្លឹងសរសៃសក់ទន់រលើបបោកបក់រវេចលម្អពត់ពេនលើផែនថ្ពាល់ក្រហមដោយកំហឹងនិងភាពទច់ទ័ល។ ម្រាមប្រុសកម្លោះលើកមកវាសថ្នម តែត្រូវខាងស្រីគេចចុះឡើងបង្ហាញថា នាងពិតជាមិនចង់បានកាយវិការព្រានរបស់គេបន្ថែមតទៅទៀតទេ។

«បើក្នុងចិត្តដឹងហើយថាខ្ញុំជាប្អូនថ្លៃ ក៏គួរចេះមើលខ្លួនឯង គោរពខ្លួនឯងខ្លះ!»

នាងថាឱ្យរអាក់រអួល ធ្វើឱ្យខាងបុរសប្រែទឹកមុខស្មើ។ គេនិយាយតិចល្មមតែឮពីរនាក់៖

«ប្អូនថ្លៃចរិតញ៉ែងញ៉ង ដើរហើរមិនសមជាស្រីមេម៉ាយប្ដីទើបនឹងស្លាប់! ស្លៀកពាក់ឆើតឆាយ ឃើញប្រុសស្អាតញញឹមដាក់មិនរើសមុខ មានប្រុសកម្លោះបណ្ដាក់គ្នាខលមកជាប់តាមផ្លូវ! ត្រូវដំបងសមណាស់»

នាងធ្មេចភ្នែកទាំងសងនឹកដល់កំហុសនៃបេះដូងខ្លួន ដែលតាមការពិតស័យណាស់មកប៉ះប្រុសសង្ហាជាបងថ្លៃវិកលចរិតម្នាក់នេះមើលច្រឡំថាគេជាសុភាពបុរស ហើយនៅមិននៅត្រូវគេចាប់បានចំណុចខ្សោយពេញដៃ។ ភាពអៀនខ្មាសនិងខូចចិត្តមិនអាចមានអ្វីប្រមូលដាក់ទុកខ្ទប់ជិតបិទបាំងបានក្រៅពីធ្មេចភ្នែកបំបាត់អាម៉ាស់មួយគ្រានោះទេ។

«ដើរហើរកែឈ្មោះ បន្លំអត្តសញ្ញាណ! មនុស្សស្រីជាប្អូនថ្លៃរបស់ខ្ញុំ តាមពិតចរិតពេញមួយ Promotions អ៊ីចឹងហ្ន៎! បើប្ដីនៅ មុខតែត្រូវរបស់ប្ដីធ្ងន់ហើយ! តែពេលនេះបងថ្លៃប្រដៅជំនួស គ្មានអីចម្លែកផងទេ!»

នាងខាំមាត់លើសដើមទ្រាំទទួលយកការខឹងដងស្ដីថា។

បុរសឃើញនាងអាណិតណាស់ទៅហើយ តែបើមិនបានថាឱ្យដឹងខ្លួនខ្លះ ក៏អាចនាងមិនចោលចរិតឃើញប្រុសស្អាតមិនបានហ្នឹងដែរ។

គេរៀបនឹងស៊កសៀតឱ្យបន្ថែម ស្រាប់តែសំឡេងអ៊ុនរាយការណ៍មកតាមកាសផ្ទប់ត្រចៀកៈ

«បងគីម៉ាល់! យើងយើងដល់ស្ទឹងត្រែងហើយ! ម្ភៃនាទីទៀតដល់កំពង់»

នាងស្តាប់ឮដំណឹងតាមសូរសំឡេងជ្រាតស្រួយស្រីបនៃឧបករណ៍ក្នុងត្រចៀកប្រុសស្អាតនោះបានជាស្រីស្រស់បើកភ្នែកមកវិញខ្វាក។

បបូរមាត់គីម៉ាល់ស្វាគមន៍នាងដោយស្នាមញញឹមស្មើ តែញញឹមចាញ់កែវភ្នែកគេទាំងសង ដែលសម្លឹងហាក់ចង់គ្រប់គ្រងជីវិតនាង រាងកាយនាងនិងបេះដូងនាង។

«ខ្ញុំជូននាងដល់ដល់គោលដៅតាមពាក្យសន្យាហើយមនុស្សស្អាត!»

គេគិតម្នាក់ឯងក្នុងចិត្ត តែមិននិយាយទេ។ ភាពរំភើបអរសប្បាយលេចឡើងលើផ្ទៃមុខចំណាប់ខ្មាំងតូចម្នាក់នេះ។ ហេតុអ្វីគីម៉ាល់យល់ថាសុភមង្គលនាងធ្វើឱ្យអ្នកហាក់សប្បាយចិត្តដល់ម្ល៉ឹង?

នាងរេសម្លឹងច្រាំងហើយចាកចេញរត់គេចទៅខាងក្រៅ។

នាងស្គាល់តំបន់នេះច្បាស់ ម្ល៉ោះហើយ ហាន់ដាញញឹមម្នាក់ឯងកំដរទិដ្ឋភាពថ្ងៃជ្រាលជ្រេលើដងទន្លេប៉ប្រឹមពណ៌មាស។

ស្ទឹងត្រែង!

បេះដូងនាងប្រាប់ថា លើកនេះគ្មានអ្នកណាហាមឃាត់ស្រីបានទៀតឡើយព្រោះសូម្បីហក់ចុះហែលទឹកក៏នាងនឹងធ្វើបានដើម្បីគេចចេញពីប្រុសចម្លែកម្នាក់នេះ។

«បើទោះជាអ្នកណាម្នាក់ មានកន្ទុយវែងជាងផ្សោត ចេះមុជដល់ជ្រលងភុជង្គនាគ កុំគិតឱ្យសោះរឿងគេចវេស!»

គេនិយាយមកពីក្រោយស្នាស្រីស្រស់។

នាងទម្លាក់ចោលស្នាមញញឹមដោយទោមនស្ស។ ហាន់ដាមិនចង់បែរក្រោយទេ នាងគិតថា២០នាទីទៀតប៉ុណ្ណោះ នាងត្រូវអត់ធន់ឱ្យបានដូច្នេះហើយប្អូនស្រីថ្លៃ មិនតបត មិនបែរក្រោយ ធ្វើមិនឮតាំងចិត្តថាមិនរវល់!

ស្រាប់តែដង្ហើមបុរមកដល់កាន់តែកៀក គឺកៀកដល់ថ្ពាក់នាងមួម៉ៅសមាធិធ្វើចិត្តលែងចង់បាន។

សំឡេងបុរសជាបងថ្លៃ និយាយមកបន្ថែម៖

«បានដល់ផ្ទះហើយអាចសប្បាយចិត្តបណ្ដោះអាសន្នបានដុកទ័រ! តែស្អែកល្ងាចយើងមកជួបគ្នាជម្រះរឿងរ៉ាវឱ្យរួចរាល់!»

នាងធ្មេចភ្នែក ព្រោះមិនចង់ធ្វើព្មមិនចង់តបត។

«ម៉ោង៦ល្ងាចនឹងមានគេផ្ញើទីតាំងឱ្យហើយ!» បុរសបន្ថែមរហូតដល់ខាងស្រីលែងអាចអំណត់ចិត្ត។

«គិតថា ខ្ញុំមកពាក់ព័ន្ធអ៊ីចឹងអ្ហែស?!»

នាងនិយាយញាប់ស្មេបន្តកន្ទុយពីសម្ដីនាយព្រោះទ្រាំលែងបាន។ នាងបែរក្រោយមកប្រឈមនឹងទឹកមុខឌឺមួយទំហឹងរបស់ប្រុសស្អាត។

ពន្លឺភ្នែកមមីរបស់គេសម្លឹងប្រតិកម្មនាងដោយអំណត់។ បុរសនេះស្ងៀមសម្ងាត់នាងរឹតតែក្នាញ់ឡើង។ គេគិតអី? គិតថាយើងឡើងគោកហើយនឹងត្រឡប់មកឱ្យគេលេងសើច ផ្ដល់ក្ដីអាម៉ាស់ឱ្យបន្ថែមហ្មែន?

ទុកយើងជាល្បែងមិនទាន់គ្រប់គ្រាន់?

«យើងអត់មានអីត្រូវជម្រះ អត់មានអីត្រូវនិយាយ ថែមទាំងអត់មានអីត្រូវជួប!»

នាងអាក់ខាន ពេលគេញញឹមស្មើៗសម្លឹងភក្ត្រស្រីក្បែរបង្កើយ។ ពន្លឺភ្នែកនិងស្នាមញញឹមបែបចំអកនេះនាំនាងឱ្យនិយាយបង្ហើយដាច់ណាត់៖

«ឬសូម្បីតែចងចាំគ្នា!...គឺគ្មានទេគីម៉ាល់! សូន្យភាគរយ!»

នាងបិទបបូរមាត់ដ៏ស្រស់រលើបនៅនឹងកែវភ្នែកមមីរបស់គេ។